## ឧបសម្ព័ន្ធទី ២ ៖ ម៉ាទ្រិកផែនការសកម្មភាពគោលនយោបាយទូទៅរបស់វិស័យអប់រំ

| វត្ថុបំណងគោលនយោបាយ និង វត្ថុបំណងរយៈពេលមធ្យម | សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៥ | សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៦ | សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៧ |
|---|---|---|---|
| ១. បង្កើនលទ្ធភាពនៃការទទួលការអប់រំប្រកបដោយសមធម៌ | | | |
| ក) បង្កើនការផ្តល់សេវាអប់រំកំរិតអប់រំមូលដ្ឋាននៅគ្រប់កំរិតទាំងអស់ប្រកបដោយសមធម៌ ។ | - ក្រសួងអប់រំយុវជននិងកីឡារៀបចំផែនការសកម្មភាពសំរាប់ធានាឱ្យមានការអប់រំមូលដ្ឋាននៅគ្រប់កន្លែង ព្រមទាំងមានផែនការចំពោះ សាលារៀនដែលមានមិនគ្រប់កំរិតថ្នាក់(ពីថ្នាក់ទី១-៦) និង ផែនការកសាងអគារសិក្សាតាមគំរូដែលធានាប្រសិទ្ធភាពនៃចំណាយ ។<br>- ក្រសួងអប់រំ យុវជន និង កីឡា នឹងបង្កើតគណៈកម្មការគ្រប់គ្រងបុគ្គលិកថ្នាក់ខេត្ត-ក្រុង និងរៀបចំផែនការសកម្មភាពសំរាប់ឆ្នាំ ២០០៥-០៦ ដើម្បីពង្រាយបុគ្គលិកទៅកាន់សាលារៀនដែលពង្រីក ឬទើបសង់ថ្មី ។ | - ក្រសួងអប់រំ យុវជន និងកីឡានឹងរៀបចំផែនការសកម្មភាពសំរាប់ឆ្នាំ២០០៦-០៧ ដើម្បីពង្រាយបុគ្គលិកទៅកាន់សាលារៀនដែលពង្រីក ឬទើបបង្កើតថ្មីព្រមទាំងរៀបចំរបាយការណ៍នៅឆ្នាំ២០០៥ ។ | - ក្រសួងអប់រំ យុវជន និង កីឡា នឹងរៀបចំផែនការសកម្មភាព សំរាប់ឆ្នាំ២០០៧-០៨ ដើម្បីពង្រាយ បុគ្គលិកទៅកាន់សាលារៀនដែលពង្រីក ឬ ទើបសង់ថ្មី ព្រមទាំងរៀបចំរបាយការណ៍នៅឆ្នាំ២០០៦ ។ |
| ខ) លុបបំបាត់ឧបសគ្គរាំងដល់ការចូលរៀន នៅកំរិតអប់រំមូលដ្ឋាន ជាពិសេសកុមារក្រីក្រ កុមារី ជនជាតិភាគតិច និងជនពិការ ។ | - ក្រសួងអប់រំ យុវជន និង កីឡា ចេញប្រកាសលុបបំបាត់រាល់ចំណាយក្រៅផ្លូវការនៅបឋមសិក្សា និងមធ្យមសិក្សា និងមានការដាក់ទណ្ឌកម្មប្រកបដោយប្រសិទ្ធភាពផងដែរ ។ | | - ក្រសួងអប់រំ យុវជន និង កីឡានឹងផ្សព្វផ្សាយរបាយការណ៍ស្តីពីផលប៉ះពាល់របស់កម្មវិធីអាហារូបករណ៍ នៅមធ្យមសិក្សាបឋមភូមិសំរាប់សិស្សក្រីក្ររបស់អង្គការ JFPR និងពីប្រភពហិរញ្ញវត្ថុផ្សេងៗទៀត ដោយរួមទាំងការកែតម្រូវយុទ្ធសាស្ត្រផងដែរ ។ |

| | | | |
|---|---|---|---|
| គ) ផ្តល់ជំនួយឧបត្ថម្ភដែលបានកំណត់ដល់សិស្សក្រីក្រ នៅថ្នាក់ទី ១០-១២។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំផែនការសកម្មភាពសំរាប់អភិវឌ្ឍសាលាមធ្យមសិក្សាទុតិយភូមិគំរូ ដោយរួមទាំងគោលនយោបាយសំរាប់ការចូលរៀន និងយន្តការនៃការផ្តល់ហិរញ្ញប្បទាន ប្រកបដោយនិរន្តភាព។ | - ក្រសួងអប់រំ យុវជន និងកីឡានឹងបែងចែកថវិកាសំរាប់ឆ្នាំ២០០៧ ដោយរួមទាំងមូលនិធិគ្រប់គ្រាន់សំរាប់ផ្តល់អាហារូបករណ៍ ដល់សិស្សក្រីក្រនៅថ្នាក់ទី១០-១២ ស្របនឹងវត្ថុបំណងរបស់ ADB ។ | |
| ឃ) ពង្រីកភាពជាដៃគូសាធារណៈ-ឯកជនសំរាប់ការបន្តការសិក្សានៅឧត្តមសិក្សា។ | | - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំ យុវជន និង កីឡា នឹងចេញអនុក្រឹត្យរួមគ្នាមួយស្តីពីការប្រែក្លាយ សាកលវិទ្យាល័យសាធារណៈមួយចំនួនឱ្យមាន លក្ខណៈជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ PAIs ។ | - ក្រសួងអប់រំ យុវជន និង កីឡាចេញ សេចក្តីណែនាំសំរាប់ដំណើរការគ្រឹះស្ថាន ឧត្តមសិក្សានៅតាមខេត្ត-ក្រុង ដោយគិតទាំងផ្នែកសាធារណៈ និងឯកជន |

| **វត្ថុបំណងគោលនយោបាយ និង វត្ថុបំណងរយៈពេលមធ្យម** | **សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៥** | **សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៦** | **សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៧** |
|---|---|---|---|
| ២. ការបង្កើនគុណភាព និង ប្រសិទ្ធភាពផ្ទៃក្នុងនៃសេវាអប់រំ | | | |
| ក) បង្កើនស្ថេរភាពនៃរចនាសម្ព័ន្ធកម្មវិធីសិក្សា និងបង្កើនម៉ោងសិក្សារបស់សិស្ស ។ | | - ក្រសួងអប់រំ យុវជន និង កីឡាចេញប្រកាសស្តីពីការកែលំអម៉ោងសិក្សា ដោយរួមទាំងផែនការសកម្មភាពរយៈពេល៣ឆ្នាំ សំរាប់បង្កើនម៉ោងសិក្សាទាំងក្នុង និង ក្រៅសាលារៀន និងកំណត់កាលបរិច្ឆេទ ដើម្បីលុបចោលការប្រជុំបច្ចេកទេសគ្រូរៀងរាល់ថ្ងៃព្រហស្បតិ៍។ | |
| ខ) បង្កើនប្រសិទ្ធភាពផ្ទៃក្នុងនៅ បឋមសិក្សា និងមធ្យមសិក្សា ។ | - ក្រសួងអប់រំ យុវជន និង កីឡាចេញប្រកាស សំរាប់កំណត់ការឡើងថ្នាក់ពីថ្នាក់ទី១-៩ ឱ្យស្របទៅនឹងចំណុចដៅរបស់ ESP រួមទាំងផែនការសកម្មភាពសំរាប់អនុវត្តថ្នាក់បំប៉ន និងការធ្វើតែសការសិក្សារបស់សិស្សក្នុងក៏រិតថ្នាក់មួយចំនួននៅបឋមសិក្សា។ | | - ក្រសួងអប់រំ យុវជន និង កីឡាចេញប្រកាស និងគោលការណ៍ណែនាំប្រតិបត្តិ ដើម្បីធានាឱ្យអត្រាឆ្លងភូមិសិក្សាពីទី ៦-៧ ស្មើ នឹង ៩៥% នៅឆ្នាំ២០០៨ ដោយមានការឃោសនាជាសាធារណៈនៅទូទាំងប្រទេស។ |
| គ) រក្សានិរន្តរភាពនៃការផ្គត់ផ្គង់សំភារៈសិក្សា | - ក្រសួងអប់រំ យុវជន និង កីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចេញអនុក្រឹតអន្តរក្រសួងស្តីពីលក្ខណៈនាពេលខាងមុខរបស់គ្រឹះស្ថានបោះពុម្ភ និង ចែកផ្សាយ និងឯកភាពលើបែបបទការងារហិរញ្ញវត្ថុ អភិបាលកិច្ច និងការងារលទ្ធកម្ម។ | - ក្រសួងអប់រំ យុវជន និង កីឡាដាក់ចេញ នូវផែនការសកម្មភាព សំរាប់ធ្វើឱ្យសៀវភៅសិក្សាមានភាពសាមញ្ញ និងកាត់បន្ថយទំហំអត្ថបទ និងវិសាលភាពរបស់សៀវភៅសិក្សា ដើម្បីធានាថាអាចសិក្សាចប់តាមកម្មវិធីសិក្សា។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំរបាយការណ៍រីកចំរើនស្តីពីលទ្ធភាព និងចំណុចដៅរបស់សៀវភៅសិក្សា និងការបែងចែកថវិកាសំរាប់សៀវភៅសិក្សា ព្រមទាំងការដកសាច់ប្រាក់។ |

| | | | |
|---|---|---|---|
| ឃ) បង្កើនសមធម៌ និងប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំផែនការសកម្មភាព ដើម្បីធានាសមធម៌នៃការចូលសិក្សានៅសាលាគរុកោសល្យ និងការពង្រាយទៅកាន់សាលាមធ្យមសិក្សាទើបបង្កើតថ្មីនៅតំបន់ដែលខ្វះសេវាអប់រំ។ | - ក្រសួងអប់រំ យុវជន និង កីឡាចេញប្រកាសស្តីពីតួនាទីរយៈពេលមធ្យម របស់ RTTC និង PTTCក្នុងការអភិវឌ្ឍបុគ្គលិក និង ការងារវិក្រឹតការ ឬ អភិវឌ្ឍគ្រូបង្រៀន។ | |
| ង) កែលំអប្រព័ន្ធពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ លើគ្រប់ផ្នែក និងគ្រប់ ទិដ្ឋភាព។ | - ក្រសួងអប់រំ យុវជន និងកីឡា បញ្ចប់ការកសាងស្តង់ដាអាំងឌីកាទ័រគុណភាព និង រៀបចំផែនការសកម្មភាព ដោយគិតទាំងការបណ្តុះបណ្តាលស្តីពី យន្តការនៃការពិនិត្យតាមដានគុណភាព និង ប្រសិទ្ធភាពអប់រំលើគ្រប់វិស័យ និង គ្រប់ទិដ្ឋភាព។ | - ក្រសួងអប់រំ យុវជន និង កីឡាចេញប្រកាស និងគោលការណ៍ណែនាំស្តីពីការពិនិត្យ តាមដានការបំពេញការងារវិស័យអប់រំ លើផ្នែកគុណភាព និង ប្រសិទ្ធភាពអប់រំលើគ្រប់វិស័យ និង គ្រប់ទម្រង់ទាំងអស់ ដើម្បីរាយការណ៍ជូនទៅថ្នាក់កណ្តាល ។ | - ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្សព្វផ្សាយរបាយការណ៍ជាសាធារណៈស្តីពី គុណភាព និង ប្រសិទ្ធភាព នៃការបំពេញការងារវិស័យអប់រំ តាមរយៈបើកសិក្ខាសាលា និង តាមរយៈបណ្តាញផ្សព្វផ្សាយដល់មុខសញ្ញា ទទួលការអប់រំ នៅតាមខេត្ត-ក្រុង និងថ្នាក់កណ្តាល។ |
| ច) កែលំអប្រព័ន្ធពិនិត្យតាមដានការសិក្សា និង ស្តង់ដារបស់សិស្ស។ | - ក្រសួងអប់រំ យុវជន និង កីឡា នឹងចេញប្រកាសស្តីពីការអនុវត្តតែសការសិក្សារបស់សិស្សនៅថ្នាក់ទី ៣, ៦ និង ទី៩ នៅទូទាំងប្រទេស ព្រមទាំងប្រើប្រាស់ការប្រលងនៅថ្នាក់ទី៩ សំរាប់ការចូលរៀននៅសាលាមធ្យមសិក្សាគំរូ។ | | - ក្រសួងអប់រំ យុវជន និង កីឡា នឹងដាក់ចេញនូវផែនការសកម្មភាព ដើម្បីធានាថាសិស្សនៅថ្នាក់ទី១២ ចំនួន ៦៥% ដែលមកពីក្រៅទីក្រុងភ្នំពេញ នឹងទទួលបានអាហារូបករណ៍ចូលរៀននៅឧត្តមសិក្សា ឬ សាលាគរុកោសល្យ ។ |
| ឆ)កែលំអក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសំរាប់ការធានាគុណភាពសេវាអប់រំ ។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំបញ្ចប់សេចក្តីព្រាងច្បាប់អប់រំ កំណត់សិទ្ធិអំណាច និងទំនួលខុសត្រូវជាផ្លូវការរបស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា និង គ្រឹះស្ថានសិក្សានានា ដើម្បីធានាបាននូវគុណភាព។ | - សេចក្តីព្រាងច្បាប់អប់រំត្រូវបានដាក់ជូនទៅសភាជាតិ ហើយក្រសួងអប់រំ យុវជន និង កីឡា នឹង រៀបចំផែនការសកម្មភាពសំរាប់រៀបចំ និង ដាក់ ចេញនូវបទបញ្ញត្តិដែលទាក់ទង។ | |

| វត្ថុបំណងគោលនយោបាយ និង វត្ថុបំណងរយៈពេលមធ្យម | សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៥ | សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៦ | សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៧ |
|---|---|---|---|
| ៣. ការកសាងសមត្ថភាពដើម្បីអនុវត្តវិមជ្ឈការការងារ | | | |
| ក) ពង្រឹងការកសាងផែនការហិរញ្ញវត្ថុទូទាំងវិស័យ និង ប្រព័ន្ធបែងចែកថវិកានៅថ្នាក់កណ្តាល និង ខេត្ត-ក្រុង។ | - ការបែងចែកថវិកាប្រចាំឆ្នាំសំរាប់ឆ្នាំ២០០៦ ស្របនឹងអាទិភាពកម្មវិធីនានា របស់ ESSP ២០០៤-០៨ ដោយមាន ៤០% ជាចំណាយមិនមែនបៀវត្ស។ | - ការបែងចែកថវិកាប្រចាំឆ្នាំសំរាប់ឆ្នាំ២០០៧ ស្របនឹងអាទិភាពកម្មវិធីនានារបស់ ESSP ២០០៤-០៨ ដោយមាន ៤០%ជាចំណាយមិនមែនបៀវត្ស។<br><br>- ក្រសួងអប់រំ យុវជន និង កីឡា អ្នកផ្តល់ជំនួយ និង NGOs ឯកភាពគ្នាលើផែនការសកម្មភាពរយៈពេល ៥ឆ្នាំ ដើម្បីធានាឱ្យមានការបន្សុីគ្នា និងការកែតម្រូវជំនួយពីខាងក្រៅ និងទម្រង់បែបបទនានា ដែលស្របនឹងអាទិភាពរបស់ ESPនិង ESSP។ | - ការបែងចែកថវិកាប្រចាំឆ្នាំសំរាប់ឆ្នាំ២០០៨ ស្របនឹងអាទិភាពកម្មវិធីនានារបស់ ESSP ២០០៤-០៨ ដោយមាន ៤០%ជាចំណាយមិនមែនបៀវត្ស។<br><br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំ យុវជន និង កីឡានឹងចេញអនុក្រឹតអន្តរក្រសួង ស្តីពីការប្រគល់ការទទួលខុសត្រូវទៅឱ្យក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកំណត់បែងចែកថវិកាអប់រំទៅដល់ខេត្ត-ក្រុង។ |
| ខ) ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចបញ្ជិការគណនេយ្យ និង ប្រព័ន្ធរបាយការណ៍នៅថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និង សាលារៀន។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំផែនការសកម្មភាពសំរាប់ការតែងតាំង និង បណ្តុះបណ្តាលគណនេយ្យករសាធារណៈ នៅតាមនាយកដ្ឋាន, BMCs និងគ្រឹះស្ថានរដ្ឋបាលសាធារណៈដោយ រួមទាំងការពង្រីកប្រព័ន្ធពតិមានគ្រប់គ្រងហិរញ្ញវត្ថុ និងរបាយការណ៍តាមប្រព័ន្ធពតិមានវិទ្យា។ | - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និង កីឡា នឹងចេញអនុក្រឹត្យរួមគ្នា ស្តីពីការតែងតាំងគណនេយ្យករសាធារណៈ នៅតាមនាយកដ្ឋាននានា BMCs និងគ្រឹះស្ថានរដ្ឋបាលសាធារណៈព្រមទាំងក្រមសីលធម៌របស់គណនេយ្យករ | - ក្រសួងអប់រំ យុវជន និង កីឡាផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបាន សរុបបញ្ចូលគ្នា និងមានភាពទូលំទូលាយ សំរាប់ឆ្នាំ២០០៦ទៅតាមទម្រង់សមស្របរបស់សវនកម្មផ្ទៃក្នុង។ |

| | | | |
|---|---|---|---|
| គ) ពង្រឹងការបំពេញការងារ និងប្រព័ន្ធសវនកម្មផ្ទៃក្នុងលើផ្នែកហិរញ្ញវត្ថុនៅថ្នាក់កណ្តាល។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំផែនការសកម្មភាពរយៈពេល៣ឆ្នាំ ដើម្បីពង្រីកប្រព័ន្ធសវនកម្មផ្ទៃក្នុង ដោយគិតទាំងការបែងចែកបុគ្គលិក និងធនធាន ។ ចំណុចដៅនៃការអនុវត្តសវនកម្ម នៅតាម BMCs ទាំងអស់ ១០០% ត្រឹមឆ្នាំ២០០៨។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំរបាយការណ៍សវនកម្មនៅតាម BMCs និងសាលារៀនជារៀងរាល់ឆ្នាំ ដោយគិតទាំងកម្មវិធីអាទិភាព ស្របនឹងចំណុចដៅរបស់ ESP។ | - ក្រសួង អប់រំ យុវជន និង កីឡា នឹងរៀបចំរបាយការណ៍ សវនកម្ម BMCs និងសាលារៀនជារៀងរាល់ ឆ្នាំ ដោយគិតទាំងកម្មវិធីអាទិភាព ស្របនឹងចំណុចដៅរបស់ ESP។ |
| ឃ) កែលំអការកសាងផែនការធនធានមនុស្ស និង ដំណើរការអភិវឌ្ឍនៅគ្រប់កំរិតក្នុងវិស័យអប់រំ។ | - ក្រសួងអប់រំ យុវជន និង កីឡាចេញប្រកាស និងគោលការណ៍ណែនាំប្រតិបត្តិលំអិត អំពីទំនួលខុសត្រូវរបស់វិទ្យាស្ថានជាតិអប់រំ ក្នុងការអភិវឌ្ឍបុគ្គលិករបស់ក្រសួង ។ | | - ក្រសួងអប់រំ យុវជន និងកីឡាដាក់ចេញនូវផែនការសកម្មភាព ស្តីពីការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍបុគ្គលិក និង គុណវុឌ្ឍិរបស់បុគ្គលិកទៅក្នុងយុទ្ធសាស្ត្រកែទម្រង់បៀវត្ស។ |
| ង) កែលំអប្រព័ន្ធគ្រប់គ្រងការបំពេញការងារ និងការពង្រាយបុគ្គលិក ។ | - គណៈកម្មការបច្ចេកទេសរួមគ្នារវាង ក្រសួងអប់រំ យុវជន និង កីឡា /ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល /ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំផែនការនិងចំណុចដៅរយៈពេល៥ឆ្នាំ ដើម្បីផ្តល់រង្វាន់ដល់មន្ត្រីអប់រំ ដោយភ្ជាប់ជាមួយនឹងប្រព័ន្ធវាយតម្លៃការបំពេញការងារ និង ការលើកទឹកចិត្ត។ | - ក្រសួងអប់រំ យុវជន និង កីឡា និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នឹងព្រមព្រៀងគ្នាលើផែនការសកម្មភាពរយៈពេល បីឆ្នាំក្នុងការធ្វើសនិទានកម្ម និងការពង្រាយបុគ្គលិក (SDRAP) ដើម្បីធានាថាគ្មានស្រុកណា ដែលមានផលធៀបសិស្ស-គ្រូ តិចជាង ៥០ និងការបែងចែកបុគ្គលិកមិនបង្រៀនទាបជាង ១៥% នៅឆ្នាំ២០០៨។ | - ក្រសួងអប់រំ យុវជន និង កីឡារៀបចំរបាយការណ៍រីកចំរើន ស្តីពីផែនការសកម្មភាពសនិទានកម្ម និងការពង្រាយបុគ្គលិក (SDRAP) និងការកែទម្រង់បៀវត្ស។ |
| ច) ពង្រឹងប្រព័ន្ធពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ រួមគ្នារវាងក្រសួងអប់រំ យុវជន និង កីឡា អ្នកផ្តល់ | - ក្រសួង អយក ធ្វើការបណ្តុះបណ្តាលសមាជិកយន្តការពិនិត្យតាមដានខ្លឹមសារស្តង់ដា អាំងឌីកាទ័រគុណភាព និង ប្រសិទ្ធភាពអប់រំលើគ្រប់វិស័យ និងការអនុវត្តស្តង់ដាប្រកបដោយ | - ក្រុមគុណភាពអប់រំរបស់ក្រសួងអប់រំ យុវជន និង កីឡានឹងធ្វើការ ពិនិត្យតាមដានការបំពេញការងារវិស័យអប់រំលើគ្រប់ផ្នែក និង គ្រប់ទិដ្ឋភាព | - ក្រសួងអប់រំ យុវជន និង កីឡានឹងបង្ហាញរបាយការណ៍បំពេញការងារវិស័យអប់រំ នៅរៀងរាល់ចុងឆ្នាំ ពីឆ្នាំ២០០៥-០៨។ |

| | | | |
|---|---|---|---|
| ជំនួយ NGO និងអ្នកពាក់ព័ន្ធដទៃទៀត ព្រមទាំងក្រុមគុណភាពអប់រំ នៃគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា ។ | ប្រសិទ្ធភាព និងទទួលបានលទ្ធផលខ្ពស់ ។ | និងរៀបចំរបាយការណ៍ ស្តីពីលទ្ធផលពិនិត្យតាមដានគុណភាព និង ប្រសិទ្ធភាពអប់រំ ។ | |

| **វត្ថុបំណងគោលនយោបាយ និង វត្ថុបំណងរយៈពេលមធ្យម** | **សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៥** | **សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៦** | **សកម្មភាពគោលនយោបាយ ពាក់កណ្តាលឆ្នាំ ២០០៧** |
|---|---|---|---|
| **៤. ធានាឱ្យការប្រមូលធនធានសំរាប់វិស័យអប់រំបានកើនឡើង** | | | |
| ក) បង្កើតគោលនយោបាយថ្នាក់ជាតិ និងក្របខ័ណ្ឌស្ថាប័ន សំរាប់វិស័យអប់រំ ។ | - ក្រសួងអប់រំ យុវជន និង កីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកភាពគ្នាលើផែនការចំណាយរយៈពេលមធ្យម ៣ឆ្នាំ (MTEP) នៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម រួមទាំងកំណើន នៃការចំណាយសំរាប់អភិវឌ្ឍ និងចំណាយចរន្តប្រចាំឆ្នាំ ដែលបំបែកដាច់ពីគ្នារវាងប្រភពធនធាន របស់រាជរដ្ឋាភិបាលនិងប្រភពធនធានពីខាងក្រៅ ។ | - ក្រសួងអប់រំ យុវជន និង កីឡាផ្សព្វផ្សាយផែនការចំណាយដែលតម្រង់ទៅរកលទ្ធផល (ROEP) សំរាប់ឆ្នាំ ២០០៧-០៩ ក្នុងរយៈពេល ៣ឆ្នាំ និងការបែងចែកថវិកាកម្មវិធី រួមទាំងលទ្ធផលនៃការបំពេញការងារវិស័យ ។ | - ក្រសួងអប់រំ យុវជន និង កីឡា នឹងរៀបចំរបាយការណ៍រីកចំរើនស្តីពីការបើកផ្តល់ថវិកា និងលទ្ធផលនៃចំណាយតម្រង់ទៅរកលទ្ធផល (ROEP) រួមទាំងការកែតម្រូវថវិកា និងយុទ្ធសាស្ត្រសំរាប់ចំណាយតម្រង់លើលទ្ធផល (ROEP) ពីឆ្នាំ២០០៨-១០ ។ |
| ខ) បង្កើនការបែងចែកថវិកាដល់វិស័យអប់រំ | - បញ្ចប់ការបែងចែកថវិកាសំរាប់ចំណាយចរន្តក្នុងវិស័យអប់រំពីថវិកាជាតិ ។ | - បញ្ចប់ការបែងចែកថវិកាសំរាប់ចំណាយចរន្តក្នុងវិស័យអប់រំ នៅក្នុងថវិកាជាតិសំរាប់ឆ្នាំសារពើពន្ធ ២០០៦ ហើយចំណែកនោះមិនត្រូវតិចជាងការបែងចែកនៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ឡើយ ។<br>- អត្រានៃការបើកផ្តល់ថវិកាសំរាប់ចំណាយចរន្តរបស់ក្រសួង អយក នៅមុនឆ្នាំ២០០៥ នឹងទទួលបានយ៉ាងតិច ៩៥% នៃចំណុចដៅដែលបានឯកភាព | - បញ្ចប់ការបែងចែកថវិកាសំរាប់ចំណាយចរន្តក្នុងវិស័យអប់រំ នៅក្នុងថវិកាជាតិសំរាប់ឆ្នាំសារពើពន្ធ ២០០៧ ហើយចំណែកនោះមិនត្រូវតិចជាងការបែងចែកនៅក្នុងឆ្នាំសារពើពន្ធ២០០៦ឡើយ ។<br>- អត្រានៃការបើកផ្តល់ថវិកាសំរាប់ចំណាយចរន្តរបស់ក្រសួង អយក នៅមុនឆ្នាំ២០០៦ទទួលបានយ៉ាងតិច ៩៧% នៃចំណុចដៅដែលឯកភាព ។ |